

# វជីមុខ និងមធុកៃតភក្នុងសិល្បៈខ្មែរ

វជីមុខ (*Vajimukha*) មានន័យថាមានព្រះកេសជាសេះ និងដងខ្លួនជាមនុស្ស។ ទេព វជីមុខ គឺជាអវតារទី១០របស់ព្រះវិស្ណុ ហើយទ្រង់ជាអ្នកបំផ្លាញសភាវអាក្រក់ និងរក្សាគម្ពីរវេទ។ ចម្លាក់ទេពវជីមុខ បន្តគោរពនៅក្នុងសិល្បៈខ្មែរ តាំងពីមុនសម័យអង្គរ ក្នុងសតវត្សទី៧នៃគ.សមក។ រហូតមានចម្លាក់រូបវជីមុខ និងមធុកៃតភ (*Madhu-Kaitabha*) បង្ហាញនៅផ្តែរប្រាសាទបន្ទាយពីរជាន់ ដែលបង្ហាញជារូបសម្លាប់បិសាចពីរនាក់បងប្អូនគឺ មធុ និងកៃតភ។ ចម្លាក់រឿងវជីមុខ និងមធុកៃតភបង្ហាញការឆ្លាក់នៅប្រាសាទបន្ទាយពីរជាន់នេះ គឺឆ្លាក់រឿង និងរូបព្រះវិស្ណុ ដែលទាក់ទងនឹងការរក្សាគម្ពីរវេទរបស់ព្រះព្រហ្ម ដែលមានប្រាង្គកណ្តាលប្រាសាទ ដង្កល់រូបព្រះព្រហ្មដ៏ធំ (រូបលេខ១-២)។



*រូបលេខ១៖ ប្រាសាទបន្ទាយពីរជាន់ឧទ្ទិសដល់ព្រះព្រហ្ម ប្រាង្គកណ្តាល(ប្រភព៖NAPV, 2020: 50)*

ដោយសារបិសាចទាំងពីរមធុ និងកៃតភ បានលួចគម្ពីររបស់ព្រះព្រហ្ម នៅពេលដែលព្រះអង្គអង្គុយសមាធិ។ ខាងក្រោមនេះនឹងបង្ហាញរឿងទេវកថាមធុកៃតភ ក្នុងអត្ថបទសាច់រឿងពីរស្រដៀងគ្នានៅឥណ្ឌា និងយកមកបង្ហាញប្រៀបធៀបនឹងសិល្បៈ

អត្ថបទដោយ៖ ជូ ជុន

ខ្មែរតាំងពីសតវត្សទី៧នៃគ.សមក។



*រូបលេខ២៖* ចម្លាក់បល្ល័ង្គព្រះព្រហ្មរាងមូល និងមានឆ្លាក់រូបហង្សជុំវិញ

អត្ថបទនេះ នឹងបង្ហាញប្រៀបធៀបចម្លាក់ទោលពីរ គឺមុនសម័យអង្គរ និងសម័យសតវត្សទី១០ នៃគ.សក្នុងរាជព្រះបាទជ័យវរ្ម័នទី៤ប៉ុណ្ណោះ។

រឿងវជីមុខ និងមធុកៃតភសរសេរជាភាសាសំស្រ្កឹត គឺនិយាយពីទេវអាក្រក់ (បិសាច) នៅក្នុងសំណេរព្រហ្មញ្ញសាសនា។ មធុ និងកៃតភនេះ កើតចេញពីក្អែលត្រចៀករបស់ព្រះវិស្ណុ នៅពេលដែលព្រះអង្គអង្គុយសមាធិ។ ទេពកើតចេញពីផ្ចិតរបស់ទ្រង់ គឺព្រះព្រហ្ម ដែលអង្គុយលើបល្ល័ង្កផ្កាឈូក។ នៅក្នុងគម្ពីភគវតបុរាណ បានកត់ត្រាថាក្នុងកំឡុងពេលបង្កើតលោក គឺមានបិសាចឈ្មោះមធុ និងកៃតភបានលួចយកគម្ពីវេទពីព្រះព្រហ្ម។ ព្រះវិស្ណុក្នុងទម្រង់ជាអវតាជាហយគ្រីវ (*Hayagriva*) ដែលជាទេពតំណាងឱ្យចំនេះដឹង និងប្រាជ្ញា ហើយមានខ្លួនជាមនុស្ស និងព្រះកេសជាក្បាលសេះ។ អវតាជាហយគ្រីវ ឬវជីមុខ បានសម្លាប់បិសាចទាំង២នេះរួចនាំយកគម្ពីវេទមកជូនព្រះព្រហ្មវិញ។[១]

សាច់រឿងទេវកថា មានសរសេរពីបិសាចទាំង២ផ្សេងមួយទៀត គឺទាក់ទងនឹងទេពព្រះនាងឧមា។ មធុ និងកៃតភ គឺមានដើមកំណើតមកពីក្អែលត្រចៀក របស់ព្រះវិស្ណុ នៅពេលបំពេញ តបធម៌គោរពដល់ព្រះនាងឧមា។ បិសាចទាំងពីរនាក់មានអាវុធ និងមន្តអាគមន៍ខ្លាំង ហើយបានចាប់ផ្ដើមវាយប្រហារព្រះព្រហ្ម។ ព្រះព្រហ្មបានដាសព្រះវិស្ណុ ដែលកំពុងធ្វើតបធម៌ឱ្យជួយលោក ប៉ុន្តែមិនអាចដាសព្រះព្រហ្មបាន ក៏បួងសួងដល់ព្រះនាងឧមា និងបន្ទាប់មកព្រះនាងជួយដាសព្រះវិស្ណុ។ បិសាចមធុ និងកៃតភបានប្រយុទ្ធជាមួយព្រះវិស្ណុ ហើយព្រះវិស្ណុបានទទួលការផ្ដល់យោបល់ពីព្រះនាងឧមា ដើម្បីទៅវាយប្រហារបិសាចទាំងពីរនេះបានជោគជ័យ។[២]

ចំណែកចម្លាក់ផ្ដែរមួយ បង្ហាញពីចម្លាក់ព្រះវិស្ណុប្រយុទ្ធជាន់ពីលើបិសាចមធុ និងកៃតភនេះ នៅប្រាសាទបន្ទាយពីរជាន់

[១] Helen and Thierry 1997: 162

[២] Helen and Thierry 1997: 162, *www.kamakoti.org*.

កោះកេរប្រាង្គផ្នែកពាយ័ព្យ និងផ្តែរផ្នែកខាងលិច គឺបង្ហាញចលនាប្រយុទ្ធគ្នាដោយដៃចាប់សក់បិសាចទាំងពីរនាក់(រូបលេខ៣-៤)។ ប៉ុន្តែប្រាសាទបន្ទាយពីជាន់នេះ ពុំឧទ្ទិសសំខាន់ទៅព្រះវិស្ណុទេ។



រូបលេខ៣៖ ផ្តែររូបវដីមុខ ប្រយុទ្ធជាមួយមធុ និងកៃតភ ផ្តែរប្រាង្គទិសពាយ័ព្យនៃប្រាសាទបន្ទាយពីរជាន់

ប្រាសាទនេះមាន ដង្កល់ទេវរូបព្រះព្រហ្មមួយដ៏ធំ នៅប្រាង្គ កណ្តាល ដែលបាត់ព្រះកេសនៅសល់តែ បល្ល័ង្គ និងបំណែកចង្កេះមួយចំនួន។ ដូច្នេះប្រាសាទបន្ទាយពីជាន់នេះ បង្ហាញយ៉ាងច្បាស់ថា ទាក់ទងសាច់រឿងដែលមានបង្ហាញក្នុងការសរសេរទាំងពីរនៅផ្នែកខាងលើ។ ឧទាហរណ៍ព្រះព្រហ្មជាអ្នកថែរក្សាគម្ពីវេទ ហើយបានលួចដោយបិសាចមធុ និងកៃតភ បន្ទាប់មកព្រះវិស្ណុបានប្រយុទ្ធយកគម្ពីមកជូនព្រះព្រហ្មវិញ។ ចម្លាក់ទោលមួយផ្សេងទៀតដែលស្ថិតក្នុងដើមសតវត្សទី១០នៃគ.សដូចគ្នា គឺស្ថិតក្នុងរចនាបថកោះកេរ ដែលនៅប្រាសាទនាងខ្មៅស្រុកបាទី ខេត្តកណ្តាល សព្វថ្ងៃនៅសារមន្ទីរជាតិភ្នំពេញ។ ប៉ុន្តែចម្លាក់នេះ ខ្មែរពេញនិយមឆ្លាក់ជាបដិមាទោល តាំងពីសម័យមុនអង្គរក្នុងដើមសតវត្សទី៧នៃគ.សមក គឺចម្លាក់ទោលវដីមុខរចនាបថភ្នំដាមកពីទួលព្រះគិន នៅគុកទ្រាបស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល សព្វថ្ងៃនៅសារមន្ទីរជាតិ (រូបលេខ៤-៥)។



រូបលេខ៤៖ វដីមុខមកពីប្រាសាទនាងខ្មៅ ខេត្តតាកាវក្នុងរចនាបថកោះកេរពាក់កណ្តាលទី១ក្នុងសតវត្សទី១០នៃគ.ស(នៅសារមន្ទីរជាតិKa.1656)។

អត្ថបទដោយ៖ ថូ ថុន



*រូបលេខ៥៖ វជីមុខមកពីទួលព្រះគិន នៅគុកទ្រាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល សព្វថ្ងៃនៅសារមន្ទីរជាតិភ្នំពេញសតវត្សទី៧នៃគ.ស*

បដិមាទោលរូបវជីមុខ រចនាបថភ្នំដានេះ បង្ហាញចលនាពង់ទុចចង្កេះ មានសម្លៀកបំពាក់ស្តើង និងមិនមែនពាក់មុតដូចក្នុងរចនាបថកោះកេរទេ។ ចម្លាក់វជីមុខមុនសម័យអង្គរនេះ ជាចម្លាក់មួយចាស់ដូចបដិមាផ្សេងៗទៀតក្នុងរចនាបថភ្នំដា ដែលទទួលឥទ្ធិពលរចនាបថគុប្តណ្ឌាខាងត្បូង[៣] ដល់សម័យក្រោយរចនាបថកោះកេរទៀត គឺក្នុងរចនាបថប្រែរូប។

សរុបសេចក្តីមកចម្លាក់រូបវជីមុខ និងមធុកៃតភមានបង្ហាញ ជាសាច់រឿងពេញប្រយុទ្ធគ្នា គឺមានតែនៅលើផ្តែរប្រាសាទក្រចាប់កោះកេរទេ ដែលបង្ហាញក្នុងប្រាសាទដែលឧទ្ទិសដល់ព្រះព្រហ្ម ភ្ជាប់ជាមួយនឹងសាច់រឿងនៅលើផ្តែរ។ ជាពិសេសសម័យកាលប្រហែលគ្នាមានការគោរព នៅប្រាសាទនាងខ្មៅស្រុងបាទី និងបន្តក្រោយរចនាបថប្រែរូបផងដែរ។ បើទោះបីមិនសូវមានការឆ្លាក់រូបវជីមុខ និងមធុកៃតភច្រើននៅមុនរាជព្រះបាទជ័យវរ្ម័នទី៤ក្នុងសម័យអង្គរ ក៏មានចម្លាក់ទោលមុនសម័យអង្គរក្នុងសតវត្សទី៧នៃគស ធំមួយដែលបង្ហាញពីការគោរពនិងឥទ្ធិពលរឿងមកបង្ហាញក្នុងសិល្បៈខ្មែរដែរ។

[៣] Helen and Thierry 1997: 162

## ឯកសារយោង

Helen and Thierry

1997. "*Sculpture of Angkor and Ancient Cambodia Millennium of Glory*", National Gallery of Art Washington, pp.162.

National Authority for Preah Vihear (NAPV)

2021. "*KOH KER: Archaeological site of Ancient Lingapura or Chok Gargyar, Nominated as a World Heritage Site*", Cambodia.

www.kamakoti.org.

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION